ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យ
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងលក្ខខណ្ឌដ៏ច្បាស់លាស់បំផុត សូមបដិសេធការអះអាងធ្វើឡើងដោយប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នបរទេសមួយចំនួន ដែលនាំឱ្យសាធារណជនជឿថា ប្រទេសកម្ពុជាប្រហែលបានអនុញ្ញាតឱ្យអ្នកដំណើរមានផ្ទុកវីរុសកូរ៉ូណា ចាកចេញ ពីកប៉ាល់ទេសចរណ៍ Westerdam ដែលការអនុញ្ញាតនេះ បង្កើនការរីករាលដាលវីរុសកូរ៉ូណាជាសកល។ អត្ថបទ និងសេចក្តីថ្លែងការណ៍មានលក្ខណៈប្រញាប់ប្រញាល់ គ្មានការយកចិត្តទុកដាក់ គ្មានវិជ្ជាជីវៈ និង មានការចោទប្រកាន់បែបនេះ បានជំរុញឱ្យមានការភ័យខ្លាច និងការភាន់ច្រលំដែលមិនគួរកើតមាន ក្នុងចំណោមសាធារណជនពាក់ព័ន្ធទៅនឹងការរីករាលដាលនៃវីរុសCOVID-19 ដែលបណ្តាលឱ្យមានការរើសអើងចំពោះអ្នកដំណើរនៃនាវា Westerdam និងមានចេតនាទុច្ចរិតមិនឱ្យតម្លៃទៅលើកាយវិការមនុស្សធម៌ និងសមត្ថភាពផ្នែកសុខាភិបាលរបស់ប្រទេសកម្ពុជា។

ដោយប្រកាន់យ៉ាងខ្ជាប់ខ្ជួនជាមួយបទបញ្ញត្តិសុខភាពអន្តរជាតិ និងសហការយ៉ាងពេញទំហឹងជាមួយអាជ្ញាធរសុខភាពដែលទទួលស្គាល់ដោយពិភពលោក រួមមាន អង្គការសុខភាពពិភពលោក (WHO) វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជម្ងឺរបស់សហរដ្ឋអាមេរិក (CDC) ក្រសួងសុខាភិបាលកម្ពុជាបានធ្វើតេស្តយ៉ាងល្អិតល្អន់លើអ្នកដំណើរ និងសមាជិកក្រុមនាវិកទាំងអស់ចំនួន ២២៥៧នាក់។ ពាក់ព័ន្ធករណីស្ត្រីជនជាតិអាមេរិក វ័យ៨៣ឆ្នាំ ដែលកាលពីមុននេះត្រូវបានគេធ្វើតេស្តរកមេរោគ COVID-19 ឃើញវិជ្ជមាន នៅប្រទេសម៉ាឡេស៊ី ត្រូវបានមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជម្ងឺរបស់សហរដ្ឋអាមេរិក ជាអាជ្ញាធរសុខភាពដែលមានការទទួលស្គាល់ជាសាកលបានបដិសេធលទ្ធផលនៃការធ្វើតេស្តនោះ និងបានបញ្ជាក់តាមរយៈអ្នកនាំពាក្យរបស់ខ្លួន ដែលបានលើកឡើងថា «ខ្ញុំសូមធ្វើការអះអាងថា អ្នកដំណើរទាំងអស់ត្រូវបានធ្វើតេស្ត នឹងរកឃើញថាមានលទ្ធផលអវិជ្ជមាន រួមទាំងស្ត្រីវ័យ៨៣ឆ្នាំនោះផងដែរ»។ លើសពីនេះទៀត ស្របគ្នាជាមួយការរកឃើញរបស់មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជម្ងឺរបស់សហរដ្ឋអាមេរិកដែរ គណៈកម្មាធិការនាយកផ្នែកការពារសុខភាពរបស់អូស្ត្រាលី (AHPPC) បានធ្វើការសម្រេចចិត្ត កាលពីថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២០ ដកចេញនូវការកំហិតឲ្យអ្នកដំណើរចេញពីកប៉ាល់ Westerdam ដោយមិនចាំបាច់ស្ថិតនៅដាច់ដោយ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ឡែកពីគេឯង រយៈពេល១៤ថ្ងៃ ដើម្បីត្រួតពិនិត្យរក COVID-19 នៅពេលត្រឡប់មកដល់ប្រទេសអូស្ត្រាលីវិញនោះទេ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមបញ្ជាក់ជាថ្មីនូវជំហររឹងមាំរបស់កម្ពុជាចំពោះការសម្រេចចិត្តរបស់ខ្លួនក្នុងការអនុញ្ញាតឱ្យនាវាទេសចរណ៍ Westerdam ចូលចតនៅក្នុងកំពង់ផែ ខេត្តព្រះសីហនុ ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកដំណើរលើនាវានោះ អាចធ្វើដំណើរដោយសុវត្ថិភាពទៅកាន់គោលដៅប្រទេសកំណើតរបស់ពួកគេរៀងៗខ្លួនវិញ។ កាយវិការរបស់កម្ពុជាបែបនេះ កើតឡើងដោយសារក្តីអាណិតអាសូរ និងមនសិការមនុស្សជាតិ ការជឿជាក់យ៉ាងជ្រាលជ្រៅទៅលើគុណតម្លៃនៃសាមគ្គីភាពនិងការទទួលខុសត្រូវជាអន្តរជាតិ ប៉ុន្តែបន្ថែមលើនេះ កម្ពុជាក៏ប្រកាន់ខ្ជាប់នូវការប្រុងប្រយ័ត្នខ្ពស់ផ្នែកវេជ្ជសាស្ត្រនិងវិទ្យាសាស្ត្រទៀតផង។ នៅចំពោះមុខបញ្ហាធ្ងន់ធ្ងរនៃការគំរាមកំហែងសុខភាពសកលនេះ ក្រសួងការបរទេស ប្រានចោលចំពោះការចុះផ្សាយដែលគ្មានការទទួលខុសត្រូវនិងគ្មានវិជ្ជាជីវៈផ្នែកសារព័ត៌មាន ដោយយោងសេចក្តីថ្លែងការណ៍ផ្លូវការមួយចំនួនរបស់បរទេស ដែលធ្វើឱ្យសាធារណជនភាន់ច្រឡំ បង្កើនការភ័យខ្លាច បង្ករសម្ពាធនិងភាពស្លន់ស្លោដែលមិនគួរមាន និងធ្វើឱ្យខូចមុខមាត់ប្រទេសកម្ពុជា៕

ថ្ងៃចន្ទ ២កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០២០